00194412

ឯកសារ/N° A 121/II

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / 06 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ក្រុមមេធាវីការពារក្តី អៀង សារី

IENG SARY DEFENCE TEAM

EQUIPE DE DEFENSE DE IENG SARY

---

អាង ឧត្តម និង Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 03 / 06 / 2008
ម៉ោង (Time/Heure): 13 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

គោរពជូន៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE
សហចៅក្រមស៊ើបអង្កេត

កម្មវត្ថុ ៖ សម្មើពាក់ព័ន្ធនឹងការសាកសួរចម្លើយលោក អៀង សារី អំពីស្ថានភាពនៃការឃុំខ្លួនរបស់គាត់ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ ២០០៨

ចៅក្រមទីជាគោរព ៖

[redacted] បន្ថែមលើនេះទៀត ភាគីចុងចោទសូមជម្រាបរំលឹកដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតអំពីសម្មើពីររបស់ភាគីចុងចោទចំពោះព័ត៌មានពាក់ព័ន្ធនឹងជម្លោះផលប្រយោជន៍យ៉ាងជាក់ច្បាស់របស់សមាជិកបុគ្គលិកពីររូបនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយករណីនេះអាចជះឥទ្ធិពលដល់ការសាកសួរ ។

---

[1] ករណីរបស់ អៀង សារី លេខស៊ើបសួរ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាចំនាំខ្លួនជនត្រូវចោទចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ ។

[លុប]

[redacted]

---

[2] ករណីរបស់ អៀង សារី លេខស៊ើបសួរ ០០២/១៩–០៩–២០០៧–អ.វ.ត.ក/ក.ស.ច.ស សេចក្តីសម្រេចឃុំខ្លួនរបស់ប៉ូលីស ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

[3] ករណីរបស់ អៀង សារី លេខស៊ើបសួរ ០០២/១៩–០៩–២០០៧–អ.វ.ត.ក/ក.ស.ច.ស ដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

[4] ករណីរបស់ អៀង ធីរិទ្ធ លេខស៊ើបសួរ ០០២/១៩–០៩–២០០៧–អ.វ.ត.ក/ក.ស.ច.ស កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស៊ើបសួរចម្លើយស្តីពីស្ថានភាពនៃការឃុំខ្លួន ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ ២០០៨ ។

[លុប]

[redacted]

ភាគីចុងចោទក៏សូមឆ្លៀតឱកាសនេះ ដើម្បីរំលឹកការិយាល័យសហចៅក្រមស៊ើបអង្កេតអំពីសំណើសុំព័ត៌មានពីមុនចំនួនពីរ ដាក់បណ្តឹងដោយភាគីចុងចោទ ពាក់ព័ន្ធនឹងជម្លោះផលប្រយោជន៍នៅថ្ងៃអនាគតរបស់លោក Stephen Heder[6] និង លោក David Boyle[7] ។

---

[5] ករណីរបស់ អៀង សារី លេខស៊ើបសួរ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើជាបន្ទាន់ ដើម្បីឲលោក អៀង សារី ត្រូវបានត្រួតពិនិត្យដោយគ្រូពេទ្យជំនាញប្រកបដោយគុណវុឌ្ឍិខ្ពស់ និង សំរាប់ការស្នាក់នៅ/ការឃុំខ្លួនបន្តរបស់គាត់ក្នុងទីកន្លែងផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រត្រឹមត្រូវ រហូតដល់បានជាសះស្បើយពេញលេញ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ("សំណើកោសលវិច័យភាគីចុងចោទ") ។

[6] ករណីរបស់ អៀង សារី លេខស៊ើបសួរ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើសុំព័ត៌មានពាក់ព័ន្ធនឹងជម្លោះផលប្រយោជន៍នៅថ្ងៃអនាគត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ("សំណើរបស់លោក Heder") ។

[7] ករណីរបស់ អៀង សារី លេខស៊ើបសួរ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើសុំព័ត៌មានពាក់ព័ន្ធនឹងភាពលំអៀងជាក់លាក់ និង ជម្លោះផលប្រយោជន៍នៅថ្ងៃអនាគតរបស់មន្ត្រីច្បាប់ឈ្មោះលោក David Boyle នៃការិយា-ល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៨ ("សំណើរបស់លោក Boyle") ។

សូមបញ្ជាក់ផងដែរថា លោក Heder ត្រូវបានផ្តាច់ចូលទៅការិយាល័យសហព្រះរាជអាជ្ញា ចាប់តាំងពីខែកក្កដា មកដល់ត្រឹមខែធ្នូ ឆ្នាំ២០០៦ ហើយការិយាល័យសហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា ខ្លួនមិនបានរកឃើញនូវហេតុផលណាមួយ ដែលជាការព្រួយបារម្ភពាក់ព័ន្ធនឹងការ–ផ្តល់ការងារដល់លោក Heder នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតឡើយ ដ្បិត "យុត្តិសាស្ត្ររបស់តុលាការដែលពាក់ព័ន្ធ រំលឹកថា វិធាននានាដែលឃ្មុំគ្រងវិសមិតភាពនៃតួនាទី ក្នុងការធានានូវឯករាជ្យភាព និង ភាពមិនលំអៀងនៃសាលាក្តី គឺអនុវត្តចំពោះតែចៅក្រម និង គឺមិនចំពោះអ្នកស៊ើប–អង្កេតឡើយ"[៨]។ ក្នុងនោះមានការថែងថា គ្មានយុត្តិសាស្ត្ររបស់តុលាការ ដែលពាក់ព័ន្ធណាមួយត្រូវបានផ្តល់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលអាចនឹងគាំពារសេចក្តីអះអាង ដែលអ្នក–ស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនចាំបាច់ត្រូវមានឯករាជ្យភាព និង ភាពមិនលំអៀងឡើយ ។ ក្នុងនោះ មានគូសបញ្ជាក់បន្ថែមទៀតថា លោក Heder បានប្រកាសយ៉ាងចំហរ និង យ៉ាងច្បាស់ថា លោក អៀង សារី មានទោសអំពីបទឧក្រិដ្ឋកម្មផ្សេងៗ ក្នុងអំឡុងពេលពាក់ព័ន្ធ ដែលមានបញ្ហា ដែលការលើកលែងទោស និង ការអនុគ្រោះទោសពីព្រះមហាក្សត្រទៅជា(ឬគួរតែ) មិនគួរត្រូវបានអនុវត្ត ហើយថា គាត់គួរត្រូវបានកាត់ទោស ។ ដោយគ្មានមន្ទិលសោះឡើយ សេចក្តីអះអាងទាំងនេះរបស់លោក Heder ត្រូវបានដឹងឮដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត (ដ្បិតសេចក្តី–អះអាងទាំងនេះគឺធ្វើឡើងដោយអតីតនិយោជិករបស់គាត់ គឺការិយាល័យសហព្រះរាជអាជ្ញា) ។ វាពិតជាគួរឲចំអកយ៉ាងខ្លាំង ដែលទាំងការិយាល័យសហចៅក្រមស៊ើបអង្កេត និង ការិយាល័យសហ–ព្រះរាជអាជ្ញាមិនបានដឹងអំពីអត្ថបទរបស់លោក Heder (សហនិពន្ធជាមួយ Brian D. Tittemore) ក្រោមចំណងជើងថា៖ *បេក្ខជនប្រាំពីរនាក់សំរាប់ការកាត់ទោស៖ ការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម* ដែលត្រូវបានបោះពុម្ភជាថ្មីក្នុងកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានៅភ្នំពេញក្នុងខែមិនា ឆ្នាំ២០០៤ ។ សំនួរអំពីកិច្ចការនេះគឺថា ការិយាល័យសហ–ចៅក្រមស៊ើបអង្កេតត្រូវបានផ្តល់ទំនុកចិត្តឲអនុវត្តនូវការស៊ើបអង្កេតមិនលំអៀងមួយ ប្រសិនបើខ្លួនចាត់ឲអ្នកស៊ើបអង្កេត ដែលជាក់ច្បាស់ថាមានភាពលំអៀង ។ នេះគឺជាការព្រួយបារម្ភដ៏ធំមួយនៅ

---

[៨] ករណីរបស់ អៀង សារី លេខស៊ើបសួរ ០០២/១៩–០៩–២០០៧–អ.វ.ត.ក/ក.ស.ច.ស លិខិតពាក់ព័ន្ធនឹងសម្នើសុំព័ត៌មានទាក់ទិននឹងជម្លោះផលប្រយោជន៍ជាយថាហេតុ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ("មានបន្ថែមការគូសបញ្ជាក់")។

ពេលពិចារណាថា វានឹងអាចទៅជាអ្នកស៊ើបអង្កេតបែបនោះ និង ចៅក្រមមិនឯករាជ្យ ដែលកំពុងតែនិយាយប្រយោគសម្បថ ។

ចំពោះសម្ដីរបស់លោក Boyle គ្មានការឆ្លើយតបណាមួយត្រូវបានផ្ដល់ជូនដោយការិយាល័យសហចៅក្រមស៊ើបអង្កេតឡើយ ។ សំនួរជាលាយលក្ខណ៍អក្សរមួយឈុតត្រូវបានប្រគល់ជូនក្នុងបំណងកំណត់អំពីភាពសមស្របផ្នែកសីលធម៌ និង ផ្នែកវិជ្ជាជីវៈរបស់លោក Boyle ដើម្បីក្លាយជាបុគ្គលិករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូចលោក Heder ដែរ មន្ត្រីច្បាប់ Boyle បានបង្ហាញដោយចំហរ និង យ៉ាងច្បាស់នូវការមិនចូលចិត្តដោយលំអៀងចំពោះលោក អៀង សារី ។ ដូច្នេះការិយាល័យសហចៅក្រមស៊ើបអង្កេត គួរពិចារណាដោយប្រុងប្រយ័ត្ននូវសម្ដីរបស់ភាគីចុងចោទពាក់ព័ន្ធនឹងលោក Boyle និង ផ្ដល់នូវការឆ្លើយតបឱបានរួសរាន់ ។

បន្ទាប់ពីពិចារណានូវកាលៈទេសៈកន្លងមក និងជាមួយនឹងសេចក្ដីគោរព ភាគីចុងចោទសូមស្នើថា ទាំងលោក Heder និង លោក Boyle មិនគួរមានវត្តមានក្នុងអំឡុងពេលសាកសួរចម្លើយលោក អៀង សារី ឡើយ ។

សូមដាក់ជូនដោយសេចក្ដីគោរព ។

ត្រា និង ហត្ថលេខា

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី